**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ: ៧២/២០១៦ កបធ.សសរ

# សេចក្តីសម្រេច

## ស្តីពីការបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ
- យោងការសម្រេចរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងអង្គពិធីផ្ទេរភារកិច្ចសមាជិក សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦
- យោងការសម្រេចរបស់កិច្ចប្រជុំពេញអង្គក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦
- តាមការចាំបាច់ចំពោះមុខរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

**ប្រការ ១.-** ត្រូវបានបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី៧ (២០១៦-២០១៩) ដូចខាងក្រោម :

**ក្រុមទី១**

១-សម្តេច **នរោត្តម សិរិវុឌ្ឍ**

២-ឯកឧត្តម **អ៊ុត ឈន**

៣-ឯកឧត្តម **សំ ព្រហ្មនា**

**ក្រុមទី២**

១-ឯកឧត្តម **មីន ស៊ាន**

២-ឯកឧត្តម **អ៊ឹម ឈុនលឹម**

៣-សម្តេចរាជបុត្រីព្រះរៀម **នរោត្តម បុប្ផាទេវី**

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១ ២៣ ៧២០ ៩១៣, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh , ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ

**ក្រុមទី៣**

១-លោកជំទាវ **ចែម ទេយ្យរិទ្ធ**

២-សម្តេចព្រះមហិស្សរា **នរោត្តម ចក្រពង្ស**

៣-ឯកឧត្តម **ពិត តាំងសាន**

**ប្រការ ២.-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-** សេចក្តីសម្រេចនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។/

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**អ៊ឹម ឈុនលឹម**

**ចម្លងជូន:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

-តុលាការកំពូល

-រាជកិច្ច

-សាមីខ្លួន

-ឯកសារ-កាលប្បវត្តិ